ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦ អនក្រ

# សេចក្ដីសំរេច
## ស្ដីពីការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ថ្ងៃទី ០៥-០៩ ខែ ធ្នូ ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញ កិច្ចព្រមព្រៀងរវាងអង្គការពុទ្ធសាសនាជប៉ុន និងពុទ្ធសាសនាកម្ពុជា ស្ដីពីការរៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១
- បានឃើញ សំណូមពររបស់សម្ដេចព្រះសង្ឃរាជ ទេព វង្ស គណៈមហានិកាយ នាសម័យប្រជុំនៅវត្តឧណ្ណាលោម កាលពីថ្ងៃទី ០៦-០៩-២០០១ .
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់ .

## ស ម្រេ ច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោកលើកទី ៣ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ០៥ ដល់ ០៩ ខែធ្នូ ឆ្នាំ ២០០២ នៅរាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្ដម អ្នកឧកញ៉ាចៅហ្វាវាំង **គង់ សំអុល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ | ប្រធាន |
| ២- សម្ដេចព្រះពោធិវង្ស **នន់ ងែត** | ព្រះអធិការពុទ្ធិកសិក្សា និងព្រះមេគណរាជធានីភ្នំពេញ | អនុប្រធាន |
| ៣- ឯកឧត្ដម **ជា សាវឿន** | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| ៤- ឯកឧត្ដម **មិន ឃិន** | អគ្គលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធានអចិន្ត្រៃយ៍ |

៥- ព្រះវិន័យសំវរ **ឆួន រ៉ា** នាយកប្រតិបត្តិអភិបាលកិច្ចសង្ឃទូទាំងប្រទេស សមាជិក
៦- ព្រះសុធម្មកោសល **ជា សំអាន** ព្រះបាឡាត់វត្តទីវង្សា សាលាគណខេត្តកណ្ដាល សមាជិក
៧- ព្រះអរិយមុនី **លឹម សុវណ្ណ** នាយករងពុទ្ធិកវិទ្យាល័យសម្ដេច បួរ គ្រី សមាជិក
៨- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
៩- ឯកឧត្តម **អ៊ុន ទីសាអ៊ីម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
១០- ឯកឧត្តម **អ៊ុជ គីមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១១- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
១២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
១៣- ឯកឧត្តម **ម៉ុន សំ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១៤- ឯកឧត្តម **ថាច់ វ៉េន** អនុរដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក
១៥- ឯកឧត្តម **កែវ សាវុធ** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា សមាជិក
១៦- ឯកឧត្តម **អ៊ុក ចាន់** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៧- ឯកឧត្តម **ចាប ញ៉ាលីខុន** អភិបាលខេត្តសៀមរាប សមាជិក
១៨- ឯកឧត្តម **ម៉ម់ សារិន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ សមាជិក
១៩- ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២០- ឯកឧត្តម **ជា គាន** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២១- ឯកឧត្តម **វ៉ែន ទាំសី** អគ្គលេខាធិការរងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២២- ឯកឧត្តម **នេត វ៉េង** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក
២៣- ឯកឧត្តម **ហង្ស សុត** អគ្គនាយកនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
២៤- ឯកឧត្តម **វ៉ៃ ឆុយស៊ាង** អគ្គនាយកនៃក្រសួងសុខាភិបាល សមាជិក
២៥- លោក **ប៊ូន លឹមហេង** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញកិច្ចនៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

<u>ប្រការ ២</u> : គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំសន្និសីទកំពូលពុទ្ធសាសនាពិភពលោក លើកទី ៣ ឱ្យប្រព្រឹត្តទៅទទួលបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរនៃកិច្ចព្រមព្រៀង
- ទទួលពិធីបដិសណ្ឋារកិច្ច និងរៀបចំការឱ្យបានសមស្របល្អ ក្នុងកម្រិតសន្និសីទថ្នាក់អន្តរជាតិ
- រៀបចំការពារសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ចរាចរជូនគណៈប្រតិភូ និងសមាជិកអង្គសន្និសីទ ឱ្យបានគង់នូវសុវត្ថិភាពគ្រប់ទីកន្លែង
- អញ្ជើញថ្នាក់ដឹកនាំជាតិ និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ពាក់ព័ន្ធចូលរួមតាមចំនួនកំណត់ជាក់ស្ដែង
- ទទួលបន្ទុកសហការរៀបចំខ្លឹមសារ ឯកសារពាក់ព័ន្ធ និងបកប្រែភាសាប្រើការរៀបចំសន្និសីទទាំងមូល តាមកម្មវិធីកំណត់
- សហការសម្របសម្រួលប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីបង្កលក្ខណៈធ្វើការផ្សព្វផ្សាយពីខ្លឹមសារសន្និសីទឱ្យបានទូលំទូលាយ

- ទំនាក់ទំនងល្អ ជិតស្និទ្ធជាមួយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ មន្ត្រីសង្ឃជំនាញ និងភាគីជប៉ុន ដើម្បីធ្វើឱ្យសន្និសីទសំរេចលទ្ធផលល្អ
- សហការដោះស្រាយទីតាំងសម្រាប់សន្និសីទកន្លែងស្នាក់អាស្រ័យ ចង្ហាន់ ម្ហូបអាហារ ភេសជ្ជៈ រថយន្ត ផ្លាកសញ្ញាផ្សេងៗ ចាំបាច់ និងផ្នែកសុខាភិបាល
- ត្រៀមលក្ខណៈឱ្យបានល្អ បំរើដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅខេត្តសៀមរាប និងនៅទីកន្លែងផ្សេងៗទៀត តាមកម្មវិធីកំណត់ជាក់ស្តែង

ប្រការ ៣ : ក្នុងការបំពេញភារកិច្ចរបស់ខ្លួន បំរើវេទិកាសន្និសីទកំពូលនេះ ក្រៅពីថវិកាដែលមានក្នុងគម្រោង តាមស្មារតីនៃកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ គណៈកម្មការនេះ អាចលើកគម្រោងសំរាប់បំពេញបន្ថែមទៅលើចំណាយដែលខ្វះ ស្នើសុំយោបល់សំរេចពីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីមានលទ្ធភាពដោះស្រាយទាន់ពេលវេលា ។

ប្រការ ៤ : គណៈកម្មការនេះ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ ដែលមានទីតាំងនៅអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និងប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងរាល់ការងារទំនាក់ទំនងរដ្ឋបាល ។

ប្រការ ៥ : គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួនផ្សេងៗទៀត តាមសំណូមពរ និងតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៦ : ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង, រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា, គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, រដ្ឋមន្ត្រីក្រសួងពត៌មាន, រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា, សាលាក្រុងភ្នំពេញ និងឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការមួយ ត្រូវទទួលភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យសម្រេចលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០០២

ហ៊ុន សែន

ចម្លងប្រគេន-ជូន :
- គណៈសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីប្រគេន-ជូនជ្រាប"
- ដូចក្នុងប្រការ ៦
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ